## ការចាក់ថ្នាំបង្ការមេរោគ COVID មានបើកទទួលក្មេងអាយុ 5 ទៅ 11 ឆ្នាំ

*ថ្ងៃទី10 ខែវិច្ឆិកា 2021*

ក្រសួងសុខាភិបាលប្រចាំទីក្រុង ឡុងប៊ីច បានចាប់ផ្តើមការចាក់ថ្នាំបង្ការមេរោគ COVID-19 សម្រាប់ទទួលទៅកាន់ក្មេងអាយុ 5 ទៅ 11 ឆ្នាំ ។

ការចាក់ថ្នាំទៅកាន់ក្មេង គឺមានជា ដូស កម្រិតទាបរបស់ Pfizer ដែលធ្លាប់បានប្រើចាក់ទៅកាន់ក្មេងអាយុ 12 ឆ្នាំ ឬ លើសរួចមកហើយ ។ ការចាក់ថ្នាំនឹងប្រើជា ពីរ ដូស ដែលមានរយៈពេល 21 ថ្ងៃ ចន្លោះ ដូស ទីមួយ និង ដូស ទីពីរ ។

ក្មេងអាយុ 5 ទៅ 11 ឆ្នាំអាចទៅទទួលការចាក់ថ្នាំដោយមិនបង់ថ្លៃ នៅតាមមន្ទីរ គ្លីនិក ណាមួយក៏បាន ដែលស្ថិតនៅក្រោមការផ្គត់ផ្គង់ពីទីក្រុង ។ ចុចយកនៅទីនេះ ដើម្បីចំណាំមើលអំពីថ្ងៃ និង ពេលវេលាបើកសម្រាប់ការទទួលចាក់ថ្នាំនៅតាមមន្ទីរ គ្លីនិក ក្នុងខែធ្នូ ។

ត្រូវមានការតម្រូវយល់ព្រមមកពីមាតាបិតាសិនសម្រាប់មនុស្សទាំងឡាយណា ដែលមានអាយុក្រោម 18 ឆ្នាំ ។ ក្រដាសបំពេញបង្ហាញការយល់ព្រម គឺមាននៅទីនេះ ។ សុំជម្រុញឱ្យមានការណាត់ពេលជួបសម្រាប់ទៅទទួលការចាក់ថ្នាំ ។ ដើម្បីធ្វើការណាត់ពេលជួបបាន គឺសូមបើកមើលនៅតាម myturn.ca.gov ឬ ទាក់ទងជាមួយលេខទូរស័ព្ទ (562) 570-4636 ។

ក្រសួងអប់រំ ឪស្រ្តីគ ឡុងប៊ីច នៅតែបន្តចុះផ្សាយអំពីការចាក់ថ្នាំនៅតាមមន្ទីរ គ្លីនិក ប្រចាំតំបន់តាមរយៈប្រើប្រព័ន្ធតាំងបង្ហាញព័ត៌មានអនឡាញ នៅក្នុង បណ្ណិមួយ ហៅ Peachjar ។ លោកអ្នកក៏អាចស្វែងរកឃើញបានដែរអំពីការតាំង បណ្ណិ អនឡាញ នៅតាម lbschools.net ដោយជ្រើសរើសយកសញ្ញាជាផ្លែឈើ peach នៅក្បែរផ្នែកខាងលើនៃគេហទំព័រ ។

ដើម្បីទទួលព័ត៌មានកាន់តែច្បាស់អំពីការចាក់ថ្នាំបង្ការមេរោគ គឺសូមបើកមើលនៅតាម longbeach.gov/vaxlb ។